**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តក្រចេះ**
**ស្រុកចិត្របុរី**
**ឃុំថ្មគ្រែ**
**លេខ:** 003/15

# សេចក្តីសម្រេច
## ស្តីពី
## ការបង្ការ និងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- យោងព្រះរាជក្រមលេខៈនស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់។
- យោងអនុក្រឹត្យលេខ:២២ អនក្រ.ប ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ/សង្កាត់។
- យោងប្រកាសលេខៈ ២៤៤៥ ប្រ.ក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃស្តីពីការ ទទួលស្គាល់សមាសភាព សមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ ជំទប់ទី២ នៃឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។
- យោងប្រកាសលេខៈ ៣៩៧៣ ប្រ.ក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃស្តីពីការប្តូរសមាជិកក្រុមប្រឹក្សាឃុំ និងជាជំទប់ទី២ នៃឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។
- យោងស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំថ្មគ្រែ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ ស្តីពីការបង្កើតសេចក្តីសម្រេចស្តីអំពីការបង្ការ និងទប់ស្កាត់អំពើហឹង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង។

## សម្រេច

ប្រការ១៖ ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងដល់ប្រជាពលរដ្ឋ នៅក្នុងឃុំថ្មគ្រែ តាមវិធីផ្សេងៗដូចជា ការជួបជុំបងប្អូន មិត្តភក្តិ ជាពិសេសកម្មវិធីប្រជុំ និងវេទិកាផ្សេងៗនៅក្នុងសហគមន៍។

ប្រការ២៖ ព្រះសង្ឃ ដូនជី អាចារ្យ និងចាស់ព្រឹទ្ធាចារ្យចូលរួមក្នុងការបង្កើនការអប់រំដល់អ្នកប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងសហគមន៍ និងពិធីបុណ្យផ្សេងៗ។

ប្រការ៣៖ បញ្ចូលកម្មវិធី ការទប់ស្កាត់ អំពើហិង្សាលើដៃគូស្និទ្ធស្នាល ដោយសារគ្រឿងស្រវឹងចូលទៅក្នុងកម្មវិធីវិនិយោគ ឬផែនការអភិវឌ្ឍន៍ឃុំថ្មគ្រែ។

ប្រការ៤៖ បញ្ឈប់ការផ្សព្វផ្សាយ និងលក់គ្រឿងស្រវឹងនៅតាមរបង និងក្នុងសាលារៀន វត្តអារ៉ាម និងអាគារសាធារណៈរបស់រដ្ឋជាអចិន្ត្រៃយ៍។

ប្រការ៥៖ ហាមសេពគ្រឿងស្រវឹងនៅក្នុងវត្តអារ៉ាម សាលារៀន និងអាគារសាធារណៈរបស់រដ្ឋ។

ប្រការ៦៖ ហាមប្រើ និងលក់គ្រឿងស្រវឹងអោយក្មេងក្រោមអាយុ១៥ឆ្នាំ និងផ្សព្វផ្សាយពីសកម្មភាពណាដែលជាការបង្ខិតបង្ខំ និងការជម្រុញលើកទឹកចិត្តក្មេងអោយសេពគ្រឿងស្រវឹងតាមបែបគ្រប់រូបភាព គឺជាករណីខុសច្បាប់។

ប្រការ៧៖ ហាមសេពគ្រឿងស្រវឹងដែលបង្កសំលេងរំខានដល់អ្នកដទៃចាប់ពីម៉ោង១១យប់ឡើងទៅ និងការបង្កភាពឥតសណ្តាប់ធ្នាប់នៅទីសាធារណៈផ្សេងៗក្នុងឃុំ។

ប្រការ៨៖ ហាមលក់គ្រឿងស្រវឹងអោយអតិថិជនដែលស្ថិតក្នុងស្ថានភាពស្រវឹង។

ប្រការ៩៖ អាជ្ញាធរត្រូវហៅអ្នកប្រព្រឹត្តផ្ទុយពីប្រការ៤, ប្រការ៥, ប្រការ៦, ប្រការ៧ និងប្រការ៨ ដើម្បីធ្វើការអប់រំ និងណែនាំ ដោយមាន កិច្ចសន្យា។ ក្នុងករណី នៅតែមិនអនុវត្តតាមការណែនាំរបស់អាជ្ញាធរចំនួន ០៣លើក នោះ នឹងត្រូវធ្វើការផាកពិន័យលើកទី១ ជាប្រាក់ចាប់ពី១០.០០០ រៀល (មួយម៉ឺនរៀល) ទៅ ៣០.០០០រៀល (បីម៉ឺនរៀល) និង លើកទី២ ត្រូវធ្វើការផាកពិន័យទ្វេដងលើការផាកពិន័យលើកទី១។ ក្នុងករណីនៅមិនរាងចាល ត្រូវចាត់វិធានការតាមច្បាប់ជាធរមាន។

ប្រការ១០៖ សេចក្តីសម្រេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥

**តែម ណាស៊ី**

**ចម្លងជូន**

- សាលាខេត្តក្រចេះ
- សាលាស្រុកចិត្របុរី
  (ដើម្បីជូនជ្រាប)
- ក្រុមប្រឹក្សាឃុំ, ប៉ុស្តិ៍នគរបាល, មេភូមិទាំងអស់
  (ដើម្បីអនុវត្ត)

ឯកសារកាលប្បវត្តិ